អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

លេខ: ០០១/២១

២៩ មេសា ២០២១

# ការស្វែងយល់ពីក្រុមបុរសរួមភេទជាមួយបុរសនៅក្នុងប្រទេសកម្ពុជា

**( Understanding Men Who Have Sex with Men in Cambodia )**

អត្ថបទ៖ ឯកឧត្តម ឈឹម ឃិនដារ៉េត អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

## លំនាំដើម

នៅប្រទេសក្នុងតំបន់អាស៊ី និងប៉ាស៊ីហ្វិក ការឆ្លងរាលដាលនៃមេរោគអេដស៍ក្នុងចំណោមបុរសរួមភេទជាមួយបុរស ( men who have sex with men "MSM" ) កំពុងមានសន្ទុះកើនឡើង។ ក្នុងឆ្នាំ២០១៨ កន្លងមកនេះ ៣០% នៃការឆ្លងថ្មីមេរោគអេដស៍នៅក្នុងតំបន់ បានកើតមានឡើងក្នុងចំណោមMSM។

អត្រាផ្ទុក ( ប្រេវ៉ាឡង់ "Prevalence" ) មេរោគអេដស៍ក្នុងចំណោមMSM មានកម្រិតខ្ពស់ក្នុងតំបន់ទីប្រជុំជនជាងតំបន់ជនបទ។ ទីក្រុងបាងកករបស់ប្រទេសថៃ ទីក្រុងរ៉ង់ហ្គូន នៃប្រទេសភូមា និងទីក្រុងហ្សាកាតា នៃប្រទេសឥណ្ឌូនេស៊ី អត្រាផ្ទុកមេរោគអេដស៍ក្នុងចំណោមបុរសរួមភេទជាមួយបុរស តាមរយៈការប៉ាន់ស្មានមានចំនួនប្រមាណពី ២០% ទៅ២៩%។

លទ្ធផលនៃការអង្កេតមួយចំនួនបានបញ្ជាក់បន្ថែមទៀតថា បុរសរួមភេទជាមួយបុរសវ័យក្មេង កំពុងប្រឈមនឹងការឆ្លងមេរោគអេដស៍។ ឧទាហរណ៍នៅទីក្រុងបាងកក ការឆ្លងថ្មីនៃមេរោគអេដស៍មានការកើតមានឡើងជាងទ្វេដងក្នុងចំណោម MSM ដែលមានវ័យពី១៨ ទៅ២១ឆ្នាំ បើធៀបនឹងMSM ដែលមានអាយុ ៣០ឆ្នាំ។ ប្រហែលពាក់កណ្តាលនៃMSM ក្នុងតំបន់គឺមានអាយុក្រោម២៥ឆ្នាំ។ ( ប្រភព: www.avert.org )

ដោយឡែកស្ថានភាពនៃក្រុមបុរសរួមភេទជាមួយបុរសនៅក្នុងប្រទេសកម្ពុជា ក៏មានលក្ខណៈប្រហាក់ប្រហែលទៅនឹងបណ្តាប្រទេសមួយចំនួនក្នុងតំបន់អាស៊ី និងប៉ាស៊ីហ្វិកដែរ ហើយការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ នៅក្នុងប្រទេសកម្ពុជាក៏កំពុងតែជម្នះនូវឧបសគ្គនេះ ដោយការកើនឡើងនូវអត្រាឆ្លងថ្មីនៃមេរោគអេដស៍ក្នុងចំណោមក្រុមបុរសរួមភេទជាមួយបុរសវ័យក្មេង ( young MSM ) ផងដែរ។



យោងតាមព័ត៌មានវិទ្យាសាស្ត្រ របស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ (NCHADS) នៃក្រសួងសុខាភិបាលនៅឆ្នាំ២០១៩ ចំនួនMSM នៅក្នុងប្រទេសកម្ពុជាមានចំនួនប្រមាណ៨៧.៨១៧នាក់ ដែលក្នុងនោះមានអត្រាផ្ទុកមេរោគអេដស៍មានចំនួនប្រមាណ៤% អត្រាផ្ទុកជំងឺកាមរោគមានចំនួនប្រមាណ១៤.៥%។ ចំណែកឯការប្រើប្រាស់ស្រោមអនាម័យ (condom use) ជាប់លាប់មានចំនួន ៥១.៥% ក្នុងចំណោមអ្នកកំពុងប្រព្រឹត្តការរួមភេទដែលមានហានិភ័យខ្ពស់ (during high-risk sex) ៥០% ក្នុងចំណោមដៃគូជួញដូរសេវាផ្លូវភេទ (commercial partner) និងចំនួនប្រមាណ៤៥.៦% ក្នុងចំណោមដៃគូរស់នៅជាមួយគ្នាជាទៀងទាត់ (regular partner)។

ការចម្លងមេរោគអេដស៍ក្នុងចំណោមបុរសរួមភេទជាមួយបុរស ក៏អាចរួមចំណែកធ្វើឱ្យមានការរាលដាលដល់ប្រជាជនទូទៅផងដែរ ព្រោះថាក្រុមMSM ខ្លះក៏មានប្រពន្ធ និងសង្សារជាមនុស្សស្រីផងដែរ។

## តើអ្វីទៅជាបុរសរួមភេទជាមួយបុរស (MSM)?

បុរសរួមភេទជាមួយបុរស (MSM) គឺសំដៅទៅលើមនុស្សភេទប្រុសដែលមានពាក់ព័ន្ធជាមួយនឹងការរួមភេទដូចគ្នា ដោយមិនគិតពីអត្តសញ្ញាណរបស់ពួកគេទេ។ ពួកគេអាចកំណត់អត្តសញ្ញាណថាជាប្រុសស្រឡាញ់ប្រុស (gay) អ្នកស្រឡាញ់ភេទដូចគ្នា (homosexual) ឬស្រឡាញ់ភេទទាំងពីរ (bisexual)។

បុរសរួមភេទជាមួយបុរស (MSM) ម្តងម្កាល ឬជានិច្ចកាលមិនបានចាត់ទុកខ្លួនពួកគេជាអ្នករួមភេទដូចគ្នា (homosexual) ឬជាអ្នករួមភេទទ្វេ (bisexual)នោះទេ។ ពួកគេអាចរៀបការ មានប្រពន្ធមានកូន។ ដោយកត្តារើសអើងពីសង្គម និងការរើសអើងពីខ្លួនឯងផងនោះ ពួកគេបានលាក់ខ្លួនធ្វើការរួមភេទជាមួយបុរសដូចគ្នាដោយស្ងប់ស្ងាត់បំផុត។ កត្តានេះបានជះឥទ្ធិពលជាអវិជ្ជមាន ដល់ក្រុមការងារក្នុងការចុះជួបធ្វើអន្តរាគមន៍ណែនាំ អប់រំផ្សព្វផ្សាយអំពីវិធីសាស្ត្រនៃការការពារខ្លួនពីការឆ្លងមេរោគអេដស៍ និងការជំរុញឱ្យមកទទួលសេវាធ្វើតេស្តរកមេរោគអេដស៍ និងទទួលការថែទាំព្យាបាលជាដើម។

## ហេតុផលលើឥរិយាបថប្រឈមនឹងការឆ្លងមេរោគអេដស៍

ការរួមភេទរបស់MSM ធ្វើឡើងតាមរយៈរន្ធគូទ (anal sex) និងតាមមាត់ (oral sex)។ លទ្ធផលអង្កេតបានបង្ហាញថាការរួមភេទតាមរន្ធគូទ ក្នុងចំណោមក្រុមMSM ដោយមិនប្រើប្រាស់ស្រោមអនាម័យការពារមានអត្រាប្រឈមនឹងការឆ្លងមេរោគអេដស៍ខ្ពស់។ អត្រានៃការប្រើប្រាស់ស្រោមអនាម័យ (condom use) ក្នុងពេលរួមភេទរបស់MSM នៅមានកម្រិតទាប ដែលធ្វើឱ្យពួកគេប្រឈមនឹងហានិភ័យនៃការឆ្លងមេរោគអេដស៍ខ្ពស់។

តាមការអង្កេតរបស់អង្គការរ៉ាក់(RHAC)ថ្មីៗនេះ អំពីឥរិយាបថមិនបានប្រើប្រាស់ស្រោមអនាម័យក្នុងពេលរួមភេទរបស់ក្រុមMSM បានបង្ហាញដូចក្នុងរូបភាពខាងក្រោម៖




## ការកាត់បន្ថយហានិភ័យនៃប្រឈមនឹងការឆ្លងមេរោគអេដស៍

នៅក្នុងស្ថានភាពនៃការព្រួយបារម្ភពីការរើសអើងពីសង្គម ឬការរើសអើងដោយខ្លួនឯងផ្ទាល់ ក្រុមបុរសរួមភេទជាមួយបុរស ត្រូវចូលរួមទទួលយកការផ្សព្វផ្សាយអប់រំពីក្រុមការងារអេដស៍ តាមរយៈជួបផ្ទាល់ (physical outreach) ឬតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (virtual outreach) ដើម្បីទទួលបានចំណេះដឹងការពារការឆ្លង និងការចម្លងមេរោគអេដស៍ និងដើម្បីថែទាំសុខភាពឱ្យបានល្អ។

ដើម្បីចៀសផុតពីការឆ្លងមេរោគអេដស៍ និងដើម្បីឱ្យមានសុខភាពល្អ ក្រុមបុរសរួមភេទជាមួយបុរសអាចអនុវត្តនូវវិធីសាស្ត្រមួយចំនួន ដូចខាងក្រោម៖

១. ចូលរួមទទួលយកការអប់រំផ្សព្វផ្សាយអំពីមេរោគអេដស៍ និងជំងឺអេដស៍ តាមមធ្យោបាយដែលអាចធ្វើបាន។

២. ប្រើប្រាស់ស្រោមអនាម័យជាប់ជាប្រចាំ និងឱ្យបានត្រឹមត្រូវនៅរាល់ពេលរួមភេទជាមួយដៃគូ។

៣. អាចទទួលយកសេវាប្រើប្រាស់ឱសថមុនពេលប្រឈមនឹងហានិភ័យ PrEP (pre-exposure prophylaxis)។

៤. ក្នុងករណីសង្ស័យការឆ្លងដោយប្រការណាមួយ ត្រូវប្រញាប់មកទទួលយកសេវាធ្វើតេស្តរកមេរោគអេដស៍ ដោយគោលការណ៍ស្ម័គ្រចិត្ត និងលក្ខការណ៍សម្ងាត់ និងដោយឥតគិតថ្លៃនៅមន្ទីរពេទ្យរដ្ឋ។

៥. ទទួលយកសេវាថែទាំ និងព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ (Antiretroviral "ARV") ដោយឥតគិតថ្លៃនៅមន្ទីរពេទ្យរដ្ឋ ដើម្បីរក្សាសុខភាពឱ្យបានល្អ។

៦. កុំបន្តឱ្យមានការចម្លងមេរោគអេដស៍មកខ្លួនបន្ថែមទៀត និងកុំបន្តចម្លងមេរោគអេដស៍ទៅអ្នកដទៃផ្សេងទៀត (អាចត្រូវប្រឈមមុខចំពោះមុខច្បាប់តាមមាត្រា១៨ និងមាត្រា៥០ នៃច្បាប់ស្តីការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS))។

**ច្បាប់ស្តីពី**

**ការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍**

(HIV/AIDS)

**មាត្រា១៨៖** ហាមដាច់ខាតអ្នកដឹងខ្លួនឯងថា មានមេរោគអេដស៍/ជំងឺអេដស៍ ទៅប្រព្រឹត្តក្នុងចេតនាចម្លងទៅអ្នកដទៃ។

**មាត្រា៥០៖** ជនណាដែលប្រព្រឹត្តផ្ទុយនឹងមាត្រា១៨ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១០ (ដប់)ឆ្នាំ ដល់១៥ (ដប់ប្រាំ)ឆ្នាំ។

